ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
លេខ:..............................

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការសេវាផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែនធម្មតា សម្រាប់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ

**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ និងជួយសម្រួលដល់បងប្អូនមន្ត្រីរាជការ បុគ្គលិក កម្មករ កម្មការិនី របស់ក្រុមហ៊ុន រោងចក្រ សហគ្រាស ឬគ្រឹះស្ថាននានា ដែលមានការងារមមាញឹក ក្នុងពេលម៉ោងការងាររដ្ឋបាល **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** បានសម្រេចដាក់ឱ្យដំណើរការសេវាផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែនបន្ថែមនៅ **ថ្ងៃសៅរ៍** និង **ថ្ងៃអាទិត្យ** នៅទីស្នាក់ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែន ប្រចាំនៅផ្សារអ៊ីអនម៉ល (AEON Mall) សែនសុខ ចាប់ពី **ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២** នេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ..ច័ន្ទ..៧..កើត..ខែ..បុស្ស..ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី..១០..ខែ..មករា....ឆ្នាំ២០២២
**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**